សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# ការប្រៀបធៀបរវាងស្ថាប័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នព្រះមហាក្សត្រនៃប្រទេសអង់គ្លេស

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

**-កែ ហុកស្រ៊ុន** **-នុត វណ្ណៈ**

**-ជិន សារិន** **-លន់ នីដូណា**

**-ថោង សុវណ្ណ** **-ស នារុំ**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ុក ដារ៉ា**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣

**រក្សាសិទ្ធិដោយ** Khmer Famous

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកឪពុក អ្នកម្តាយដែលបានផ្តល់ជីវិត និងបីបាច់ថែរក្សាយើងខ្ញុំ ជារៀងរហូតមក ព្រមទាំងផ្គត់ផ្គង់ការសិក្សាតាំងពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា។ ដោយសារគុណូបការៈ របស់លោកអ្នកមានគុណទាំងពីរ ទើបធ្វើឲ្យយើងខ្ញុំបានរៀនសូត្រ និងមានចំណេះវិជ្ជារហូតដល់បច្ចុប្បន្ន ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំទាំងប្រាំមួយនាក់ ក៏សូមសម្តែងនូវអំណរគុណចំពោះលោកគ្រូ អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ជួយបង្ហាត់បង្ហាញ និងផ្តល់ចំណេះដឹងដល់យើងខ្ញុំទាំងអស់គ្នាតាំងពីវ័យកុមារ រហូតដល់បច្ចុប្បន្ន។ ដោយសារគុណូបការៈរបស់លោកអ្នកទាំងអស់នេះហើយ ទើបយើងខ្ញុំមានចំណេះដឹងអាចធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ពីបញ្ហានានានៅក្នុងសង្គម មានវិជ្ជាជីវៈសម្រាប់ចិញ្ចឹមជីវិត ក្លាយជាពលរដ្ឋល្អ និងចូលរួមអភិវឌ្ឍប្រទេសជាតិឲ្យបានរីកចម្រើន។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យ **ម៉ុក ដារ៉ា** ដែលបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញ ផ្តល់គំនិតសម្រាប់ធ្វើការស្រាវជ្រាវ ក៏ដូចជាការផ្តល់ដំបូន្មាន នៅក្នុងថ្នាក់រៀន ផងដែរ។

យើងខ្ញុំសូមគោរពជូនពរដល់លោកអ្នកមានគុណទាំងអស់ ឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា។

# មាតិកា


**ជំពូកទី១៖ ស្ថាប័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ................................ 1

**១.១. លក្ខណៈទូទៅនៃស្ថាប័នព្រះមហាក្សត្រ** ................................ 1

**១.២. ការជ្រើសរើសព្រះមហាក្សត្រ** ................................ 2

១.២.១ លក្ខខណ្ឌជ្រើសរើស ................................ 2

១.២.២ ការជ្រើសរើស ................................ 3

**១.៣. មុខងារ និងសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ** ................................ 4

១.៣.១ មុខងារ ................................ 4

១.៣.២ សិទ្ធិអំណាច ................................ 4

**១.៤ ព្រះជាយានៃព្រះមហាក្សត្រ** ................................ 6

**ជំពូកទី២៖ រាជានិយមនៃចក្រភពអង់គ្លេស** ................................ 7

**២.១. លក្ខណៈទូទៅនៃស្ថាប័នព្រះមហាក្សត្រ** ................................ 7

**២.២. តួនាទី និងអំណាច របស់ព្រះមហាក្សត្រ** ................................ 7

២.២.១ អំណាចជាក់ស្ដែង (Actual Prerogative Power) ................................ 8

២.២.២ អំណាចនិមិត្តរូប (Notional Prerogative Power) ................................ 9

**២.៣. ការឡើងគ្រងរាជ្យ** ................................ 10

**សេចក្ដីសន្និដ្ឋាន** ................................ 11

**ឯកសារយោង** ................................ 13

# សេចក្តីផ្តើម

នេះគឺការសិក្សាអំពី របបរាជានិយមនៅប្រទេសកម្ពុជា និង នៅចក្រភពអង់គ្លេស។ ការសិក្សានេះ ធ្វើឡើងដើម្បីស្វែងរកភាពខុសគ្នា និង ដូចគ្នានៃលក្ខណៈទូទៅ របស់រាជានិយមនៃប្រទេសទាំងពីរពិសេស គឺបង្ហាញឲ្យឃើញនូវចំណុចខ្លាំង និង ខ្សោយនៃរបបនេះនៃប្រទេសនីមួយៗ។ បន្ថែមពីនេះទៅទៀត ការសិក្សានេះគឺធ្វើឡើងដើម្បីរកឲ្យឃើញ អំពីហេតុផលចម្បងដែលនាំឲ្យមានចំនុចខ្សោយទាំងនោះ ប្រយោជន៍ដើម្បីលើកជាអនុសាសន៍ក្នុងការកែលម្អឲ្យមានភាពប្រសើរគ្រប់ប្រការដែលយល់ឃើញថា គួរកែលម្អ ពិសេសសម្រាប់របបរាជានិយមនៅកម្ពុជា។

ហេតុផលដែលនាំឲ្យមានការសិក្សាស្រាវជ្រាវនេះឡើង ដោយអាស្រ័យ យល់ឃើញពីភាពចំណាស់នៃរបបរាជានិយមនៅកម្ពុជា ដែលចាក់ឬសជាប់ក្នុងប្រវត្តិសាស្ត្រ និង ប្រពៃណីនៃប្រទេសនេះ តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន។ ដោយឡែក ដោយការវិវឌ្ឍន៍នៃដំណាក់កាលប្រវត្តិសាស្ត្រពីមួយជំនាន់ទៅមួយជំនាន់ បានធ្វើឲ្យមានលក្ខណៈប្រែប្រួលជាសារវន្តនៃរបបរាជានិយមនៅកម្ពុជា។ ម្យ៉ាងវិញទៀត ចក្រភពអង់គ្លេសក៏គោរព និង ប្រកាន់យករបបរាជានិយមតាំងពីអតីតកាល រហូតដល់បច្ចុប្បន្នមិនខុសពីប្រទេសកម្ពុជានោះដែរ ហើយការសិក្សាស្រាវជ្រាវនេះក៏ធ្វើការប្រៀបធៀបរបបរាជានិយម ដែលមានតាំងពីលក្ខណៈទូទៅ របៀបឡើងគ្រងរាជ តួនាទី និងអំណាចរបស់អង្គព្រះមហាក្សត្រនៃប្រទេសទាំងពីរ។

# ជំពូកទី១

# ស្ថាប័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

## ១.១. លក្ខណៈទូទៅនៃស្ថាប័នព្រះមហាក្សត្រ

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។[1] នេះស្តែងបញ្ជាក់ឲ្យឃើញថា ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានស្តេចសោយរាជ្យ ដែលខុសពីប្រទេសមួយចំនួន គឺមិនមានស្តេចសោយរាជ្យទេ ប៉ុន្តែគេមានប្រធានាធិបតីជាប្រមុខរដ្ឋទៅវិញ។ ព្រះមហាក្សត្រព្រះអង្គទ្រង់ ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ។

បន្ថែមពីនេះទៀត ព្រះអង្គទ្រង់ជាអ្នកធានានូវឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។ ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ដោយព្រះអង្គមិនអាចនរណារំលោភបំពានបានឡើយ។

ក្នុងករណីដែលព្រះមហាក្សត្រ ពុំអាចបំពេញព្រះរាជភារៈជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គទ្រង់មានប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញ ដែលជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធាន ព្រឹទ្ធសភានឹងបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួស ព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលនោះព្រះអង្គប្រឈួនជាទម្ងន់ ប្រធានរដ្ឋសភា ជាអ្នកបំពេញភារកិច្ចនេះ។ តំណែងជាប្រមុខរដ្ឋ ជំនួសព្រះមហាក្សត្រក្នុងឋានៈជារាជានុសិទ្ធិនេះ អាចនឹងដូចឥស្សរជនផ្សេងទៀត ទៅតាមឋានានុក្រមដូចតទៅៈ

- អនុប្រធានទី១ ព្រឹទ្ធសភា
- អនុប្រធានទី១ រដ្ឋសភា
- អនុប្រធានទី២ ព្រឹទ្ធសភា

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រា ១។

- អនុប្រធានទី២ រដ្ឋសភា

ប៉ុន្តែក្នុងករណីព្រះមហាក្សត្រទ្រង់ចូលទិវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទិវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិត្រូវអនុវត្តដូចក្នុង ករណីព្រះមហាក្សត្រទ្រង់ប្រឈួនដែរ។ ចំពោះការជ្រើសរើសព្រះមហាក្សត្រថ្មីក្នុងករណី ព្រះមហាក្សត្រចូលទិវង្គត ត្រូវធ្វើក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ ។

## ១.២. ការជ្រើសរើសព្រះមហាក្សត្រ

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង។ ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរាជទាយាទសម្រាប់គ្រង់រាជសម្បត្តិឡើយ។[2] បើយើងពិនិត្យមើលទៅ ការជ្រើសរើសយករបបរាជានិយមជ្រើសតាំងដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នេះ គឺខុសពី រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ត្រង់មាត្រា ២៦ ដែលបញ្ញត្តិថា ព្រះមហាក្សត្រទ្រង់នូវព្រះរាជអំណាច ចាត់តាំងព្រះរាជ្ជទាយាទ និងព្រះរាជអំណាចដកព្រះរាជ្ជទាយាទពីតំណែងបាន ដោយគ្រាន់តែទ្រង់ប្រជុំក្រុមប្រឹក្សារាជសម្បត្តិពិគ្រោះជាមុនសិន។

### ១.២.១ លក្ខខណ្ឌជ្រើសរើស

អ្នកដែលត្រូវបានក្រុមប្រឹក្សារាជសម្បត្តិ ជ្រើសរើសធ្វើជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លុះត្រាតែជននោះមាននូវលក្ខខណ្ឌដូចតទៅៈ

- ជាព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា
- ជាព្រះរាជបច្ឆាញាតិ នៃព្រះមហាក្សត្រអង្គឌួង ឬព្រះមហាក្សត្រនរោត្តម ឬក៏ព្រះមហាក្សត្រស៊ីសុវត្ថិ
- មុនចូលគ្រងរាជ្រសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធានជាមុនសិន។[3]

[2] ដូច ១, មាត្រា ១០។

[3] ដូច ១, មាត្រា ១៤។

### ១.២.២ ការជ្រើសរើស

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជ្យសម្បត្តិ ដែលមានសមាសភាពដូចតទៅ៖

- ប្រធានព្រឹទ្ធិសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទី១ និងអនុប្រធាទី២ ព្រឹទ្ធិសភា
- អនុប្រធានទី ១ និងអនុប្រធានទី២ រដ្ឋសភា

ចំពោះការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សារាជ្យសម្បត្តិ និង មានកំណត់ក្នុងច្បាប់មួយ។[4] ហេតុដូច្នេះហើយ ទើបនៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ ព្រះមហាក្សត្រទ្រង់ប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សារាជសម្បត្តិ។ ការប្រកាសនេះ ធ្វើឡើងបន្ទាប់ពីការដាក់រាជសម្បត្តិ របស់ព្រះមហាក្សត្រ នរោត្តម សីហនុ ។

ច្បាប់នេះមាន ៥ ជំពូក ១៨ មាត្រា និងចែងថា ប្រធានព្រឹទ្ធសភា ជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ប្រធានរដ្ឋសភា ជាអនុប្រធានទី១ ចំណែកឯ នាយករដ្ឋមន្ត្រី ជាអនុប្រធានទី២ ។ ក្រុមប្រឹក្សារាជសម្បត្តិ អាចប្រជុំបាន ប្រសិបើមានវត្តមានសមាជិកយ៉ាងតិច ៥ រូប ក្នុងចំណោមសមាជិកចំនួន ៩ រូប។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដើម្បីជ្រើសរើស ព្រះមហាក្សត្រថ្មី ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាត ហើយមិនមានមាត្រាណាមួយ ចែងពីសម្លេងឧត្តមានុភាពនោះទេ។

[4] ដូច ១, មាត្រា ១៣។

## ១.៣. មុខងារ និងសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ

បើតាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ព្រះមហាក្សត្រ ទ្រង់មានសិទ្ធិអំណាច ដែលមុខងារ និងសិទ្ធិអំណាចទាំងនោះ ជាតំណាងតាមទំលាប់ដែលមានដូចតទៅៈ

### ១.៣.១ មុខងារ

- ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការពារ ប្រព្រឹត្តទៅអំណាចសាធារណៈឲ្យមានភាពទៀងទាត់ ។[5]
- ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ប៉ុន្តែអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។[6]
- ព្រះមហាក្សត្រទ្រង់គង់ជាព្រះធិបតី នៃឧត្តមក្រុមប្រឹក្សាការពារជាតិ ។[7]

### ១.៣.២ សិទ្ធិអំណាច

- អង្គព្រះមហាក្រត្យ ទ្រង់ជាប្រមុខរដ្ឋអស់មួយជីវិត ដែលព្រះអង្គមិនត្រូវបាននរណាម្នាក់អាចរំលោភបំពានបានឡើយ។[8]

ការបំពារបំពានលើអង្គព្រះមហាក្សត្រ គឺជាបទល្មើសឧក្រិដ្ឋ។ ជាក់ស្តែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីទោសទណ្ឌ ដែលអាចកើតមានចំពោះឧក្រិដ្ឋជនដែលប្រព្រឹត្តអំពើបំពានលើអង្គព្រះមហាក្សត្រ។ ការធ្វើឃាតចំពោះអង្គព្រះមហាក្សត្រ ត្រូវដាក់ពន្ធនាគារអស់មួយជីវិត។[9] ដោយឡែក ការធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ ត្រូវដាក់ពន្ធនាគារ ពី ១០ ទៅ ២០ ឆ្នាំ។[10] ម្យ៉ាងវិញទៀត ត្រូវដាក់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំផងដែរចំពោះជនដែលប្រព្រឹត្តអំពើហឹង្សាដោយចេតនាលើព្រះអង្គ។ [11] ក្នុងករណីអំពើហិង្សាដោយចេតនាទាំងនោះ បានធ្វើឡើងរហូតដល់ការ កាត់អវយវៈព្រះអង្គ ទោសដាក់ពន្ធនាគារ នឹង

[5] ដូច ១, មាត្រា ៩។

[6] ដូច ១, មាត្រា ២៣។

[7] ដូច ១, មាត្រា ២៤។

[8] ដូច ១, មាត្រា ៧។

[9] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ២០០៩, មាត្រា ៤៣៣។

[10] ដដែល, មាត្រា ៤៣៤។

[11] ដូច ៩, មាត្រា ៤៣៥។

[11] ដូច ៩, មាត្រា ៤៣៦, ៤៣៧។

ត្រូវធ្វើឡើងចាប់ពី ១០ ទៅ ២០ ឆ្នាំ និងពី ២០ ទៅ ៣០ ឆ្នាំ ប្រសិនបើនាំឲ្យព្រះអង្គចូលទីវង្គត។[12]

- ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី ដោយធ្វើតាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ហើយព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឲ្យបង្កើតរាជរដ្ឋាភិបាល។[13]

វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តួរផ្តង់ឲ្យកាន់តំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល ដោយសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។[14]

- ការរំលាយរដ្ឋសភា តាមការស្នើសុំពីនាយករដ្ឋមន្ត្រី និងដោយមានការយល់ព្រម ពីប្រធានរដ្ឋសភា។ ក្នុងករណីប្រទេសមានសង្គ្រាម ឬកាលៈទេសៈពិសេសដទៃ ទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើព្រះមហាក្សត្រ ។ ព្រះរាជសំណើរនេះ ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបី នៃចំនួនសមាជិកសភាទាំងមូល។[15]
- ការតែងតាំង ការផ្លាសប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព តាមសេចក្តីស្នើសុំរបស់ គណៈរដ្ឋមន្ត្រី និងការតែងតាំងផ្លាស់ប្តូរ និងដកចៅក្រម តាមសេចក្តីស្នើសុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។[16]
- ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។[17]
- ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា។[18]
- ទ្រង់ឡាយព្រះហត្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ និងប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងនោះ ក្រោយការទទួលអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។[19]

[12] ដូច ៩, មាត្រា ៤៣៦, ៤៣៧។

[13] ដូច ១, មាត្រា ១៩ ថ្មី។

[14] ដូច ១, មាត្រា ១១៩ ថ្មី។

[15] ដូច ១, មាត្រា 78។

[16] ដូច ១, មាត្រា ២១។

[17] ដូច ១, មាត្រា ២២។

[18] ដូច ១, មាត្រា ២៤។

- ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស។[20]
- ទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយសជាតិតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។[21]
- ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហត្ថលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និង ទ្រង់ឡាយព្រះហត្ថលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។

ដោយឡែកព្រះមហាក្សត្រ ទ្រង់មានផងដែរនូវបុព្វសិទ្ធិជាព្រះប្រធាននៃស្ថាប័នរដ្ឋដូចជា៖

- ជាឧត្តមក្រុមប្រឹក្សាការពារជាតិ។[22]
- ជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ព្រះរាជតំណាងម្នាក់ ត្រូវបានចាត់តាំងដោយ ព្រះមហាក្សត្រ ដើម្បីធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានេះ។[23]
- សមាជជាតិ ប្រព្រឹត្តទៅក្រោមព្រះរាជធិបតីភាព នៃព្រះមហាក្សត្រ ដែលធ្វើការប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។[24]
- ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើច្បាប់ទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើធម្មនុញ្ញ ។[25]

## ១.៤ ព្រះជាយានៃព្រះមហាក្សត្រ

ព្រះជាយានៃព្រះមហាក្សត្រ មានឋានៈជាព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា។ ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ។ ព្រះមហេសីទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ចផ្នែកពិធីការ និងកាទូត ។

[19] ដូច ១, មាត្រា ២៦។

[20] ដូច ១, មាត្រា ២៧។

[21] ដូច ១, មាត្រា ២៩។

[22] ដូច ១, មាត្រា ២៥។

[23] ដូច ១, មាត្រា ១៣៤។

[24] ដូច ១, មាត្រា ១៤៨។

[25] ដូច ១, មាត្រា ១៤៣ ថ្មី។



និស្សិត៖ ជិន សារិន, កែ ហុកស្រ៊ុន, ថោង សុវណ្ណ, នុត វណ្ណៈ, ស ភារុំ, លន់ នីដូណា

សាស្ត្រាចារ្យណែនាំ៖ **ម៉ុក ដារ៉ា**

# ជំពូកទី២

# រាជានិយមនៃចក្រភពអង់គ្លេស

## ២.១. លក្ខណៈទូទៅនៃស្ថាប័នព្រះមហាក្សត្រ

អំណាចធំបំផុតរបស់ចក្រភពអង់គ្លេស ត្រូវបានប្រគល់ឲ្យប្រមុខរដ្ឋ ដែលត្រូវបានគេស្គាល់ថាជា «រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ» ។ មានន័យថាកំឡុងពេលដែលព្រះមហាក្សត្រកំពុងស្ថិតក្នុងការគ្រងរាជ្យសម្បត្តិ ព្រះអង្គគឺជាប្រមុខនៃរដ្ឋ ដែលមានសិទ្ធិគ្រប់គ្រង និងធ្វើសេចក្តីសម្រេចផ្សេងៗដោយផ្អែកលើរដ្ឋធម្មនុញ្ញ ។ ផ្សេងអំពីប្រទេសប្រកាន់របបប្រធានាធិបតេយ្យនិយម ប្រមុខរដ្ឋនៃចក្រភពអង់គ្លេស គឺជានិមិត្តរូបរបស់ជាតិ ដែលមានអំណាចតិចតួចបំផុត (figurehead) ។ ការសម្រេចទាំងឡាយទាក់ទងនឹងគោលនយោបាយរបស់ជាតិ ឬគោលនយោបាយបរទេសត្រូវបានប្រគល់ឲ្យសភា និងជាពិសេសរាជរដ្ឋាភិបាលដែលដឹកនាំដោយប្រកាន់សភា ឬនាយករដ្ឋមន្ត្រី ។

អំណាចទាំងឡាយត្រូវបានប្រគល់ឲ្យនាយករដ្ឋមន្ត្រី ដើម្បីជ្រើសរើសរដ្ឋមន្ត្រីរបស់ខ្លួន បង្កើតច្បាប់ និងធ្វើសេចក្តីសម្រេច ប្រកាសប្រទេសក្នុងសភាពមានអាសន្ន ដែលទាំងអស់នេះកើតចេញពីរាជានុសិទ្ធិ (Royal prerogative) ដែលជាមូលដ្ឋានគ្រឹះក្នុងរដ្ឋធម្មនុញ្ញ ។ តាមការពិតទាំងនេះគឺជាសិទ្ធិ និងអំណាចដែលគួរទទួលបានដោយអង្គព្រះមហាក្សត្រ បើនិយាយទៅតាមប្រពៃណីក្តី ឬប្រវត្តិសាស្ត្រក្តី ។ បច្ចុប្បន្នសិទ្ធិ និងអំណាចចម្បងទាំងអស់នោះត្រូវបានដកចេញពី គោលការណ៍នោះដោយផ្ទេរទៅសភាវិញ ។

## ២.២. តួនាទី និងអំណាច របស់ព្រះមហាក្សត្រ

របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនៃចក្រភពអង់គ្លេស បានអភិវឌ្ឍន៍ជាលំដាប់ចាប់តាំងពីឆ្នាំ ១៦៨៩ មកម្ល៉េះ ដែលពេលនោះគោលការណ៍សំខាន់ៗមួយចំនួនត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិរដ្ឋសភា និងកំណត់អំណាចរបស់អ្នកកាន់អំណាច ។

<u>**គោលការណ៍គ្រឹះទាំងនោះរួមមានៈ**</u>

- ច្បាប់គួរតែមិនស្ថិតនៅក្រោមការជ្រៀតជ្រែករបស់ព្រះមហាក្សត្រ
- រាស្ត្រអាចប្តឹងអ្នកកាន់អំណាចបាន

- អង្គព្រះមហាក្សត្រមិនអាចដាក់បន្ទុកពន្ធដារដោយរាជសិទ្ធិតែឯងបានទេ
- ការបោះឆ្នោតនៃសមាជិកសភា ត្រូវធ្វើឡើងដោយមិនមានការអន្តរាគមន៍ពីព្រះមហាក្សត្រ ។

លើសពីនេះទៅទៀត បទប្បញ្ញត្តិជាច្រើនត្រូវបានបង្កើតឡើងដើម្បីកម្រិតសិទ្ធិអំណាច របបអំណាចរាជានិយម ។ ឧទាហរណ៍ រាជានិយមនៃប្រទេសអង់គ្លេស ៖

- មិនអាចបង្កើត ឬអនុម័តច្បាប់
- ត្រូវមានអព្យាក្រឹត្យភាព
- មិនមានសិទ្ធិបោះឆ្នោត

តួនាទី និងសិទ្ធិអំណាចរបស់របបរាជានិយមអាចត្រូវបានបែងចែកជាពីរធំៗ គឺ អំណាចជាក់ស្តែង (Actual) និងនិមិត្តរូប (Notional) ។

### ២.២.១ អំណាចជាក់ស្តែង (Actual Prerogative Power)

- ព្រះមហាក្សត្រ គឺជាប្រមុខរដ្ឋ
- ប្រមុខនៃអំណាចរបស់រដ្ឋ អង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអំណាចតុលាការ
- មេបញ្ជាការកងរាជអាវុធហត្ថ
- ប្រមុខដឹកនាំនៃព្រះវិហារសាសនា
- មានអំនាចឲ្យមានការបោះពុម្ព រូបព្រះឆាយាលក្ស៍ព្រះអង្គដឹកនាំនៃព្រះអង្គដាក់លើក្រដាសប្រាក់ ឬ រូបិយវត្ថុជាតិ ។

មិនតែប៉ុណ្ណោះព្រះមហាក្សត្រក៏មានតួនាទី ពីរ ទៀតក្នុងទំនាក់ទំនងជាមួយសភា ។ តួនាទីទាំងនោះ ឃើញមានលក្ខណៈជានិមិត្តរូប ក៏ប៉ុន្តែវាបានបង្ហាញអំពីការគោរពនិងលើកតម្កើងក្នុង រដ្ឋាភិបាល ។ តួនាទីទាំងនោះគឺការបើក និងបិទនីតិកាលសភាជាតិ ។

- អង្គព្រះមហាក្សត្រធ្វើការបើកសម័យនីមួយៗ នៃរដ្ឋសភាដែលព្រះអង្គទ្រង់លើកឡើងអំពីរបៀបវារៈ នៃច្បាប់ថ្មីដើម្បីធ្វើការពិភាក្សានៅក្នុងសម័យប្រជុំសភា ។ ជាការពិតណាស់ព្រះអង្គមិនមែនជាអ្នកសរសេរ ឬថ្លែងការណ៍ តាមពាក្យព្រះអង្គផ្ទាល់ទេ ប៉ុន្តែជាការធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល ។ ទោះយ៉ាងណាក៏ដោយនេះជាការបង្ហាញថាព្រះអង្គតែងស្ថិតនៅក្នុងបេះដូងរបស់រាជរដ្ឋាភិបាល ។

- នៅពេលដែលបញ្ចប់សម័យប្រជុំនីមួយៗ និងនៅពេលបញ្ចប់និតិកាលនៃរដ្ឋសភា នាយករដ្ឋមន្ត្រី ធ្វើការស្នើសុំរាជានុញ្ញាតដើម្បីបិទ និងបញ្ចប់នីតិកាលរដ្ឋសភា ។

មិនតែប៉ុណ្ណោះ ព្រះមហាក្សត្រមានសិទ្ធិជួបជាមួយនាយករដ្ឋមន្ត្រីរៀងរាល់មួយសប្តាហ៍ម្តង ដើម្បីពិភាក្សាកិច្ចការគណៈរដ្ឋមន្ត្រី និងផ្តល់ជាយោបល់ទាក់ទងនិងកិច្ចការរបស់ជាតិ ។ ក្នុងករណីមិនអាចជួបផ្ទាល់ក្នុងលក្ខខណ្ឌពិសេសជាក់ស្តែង ជំនួបរវាងអង្គព្រះមហាក្សត្រ និងនាយករដ្ឋមន្ត្រីអាចធ្វើឡើងតាមប្រពន្ធ័ទូរសព្ទ័ ។

- ទ្រង់ជាអ្នកប្រគល់នូវគ្រឿងឥស្សរិយយស ជារង្វាន់ ឬកិត្តិយស ដល់ប្រជាជនដែលទទួលបានជោគជ័យ ក្នុងរឿងអ្វីមួយ ។
- ទ្រង់ជាអ្នកបំពេញកិច្ចការដោយសប្បុរសធម៌ផ្សេងៗ
- ដឹកនាំប្រជាជាតិទាំងមូលក្នុងការកាន់ទុក្ខ ចំពោះគ្រោះមហន្តរាយផ្សេងៗ ឬចំពោះយុទ្ធជនដែលស្លាប់ក្នុងសមរភូមិ ។
- យាងជួបជាមួយប្រជាពលរដ្ឋតាមតំបន់ផ្សេងៗក្នុងឪកាសពិសេសៗទាំងឡាយ ។

### ២.២.២ អំណាចនិមិត្តរូប (Notional Prerogative Power)

អំណាចរបស់អង្គព្រះមហាក្សត្រ គឺអាចធ្វើទៅបានដោយអាស្រ័យការផ្តួចផ្តើមរបស់រដ្ឋមន្ត្រីពិសេសគឺនាយករដ្ឋមន្ត្រី ។ តួយ៉ាងដូចជាអំណាចខាងក្រោម ៖

- រំលាយ និងកោះហៅរដ្ឋសភា មានន័យថាស្នើឲ្យមានការបោះឆ្នោត និងបង្កើតរដ្ឋសភាថ្មី បន្ទាប់ៗពីចេញលទ្ធផលឆ្នោត ។
- ផ្តល់ការយល់ព្រមចំពោះច្បាប់ដែលបង្កើតដោយសភា
- តែងតាំងរដ្ឋមន្ត្រី និងមន្ត្រីសាធារណៈ រួមទាំងចៅក្រម មន្ត្រីទូត អភិបាល មន្ត្រីក្នុងជួរទ័ព មេទាហាន និងអាចារ្យក្នុងព្រះវិហារ Church ។
- ប្រកាសសង្គ្រាម និងសន្តិភាពរបសជាតិ ។
- ប្រកាសពន្យាពេលសកម្មភាពរបស់រដ្ឋាភិបាល សម្រាប់រយៈពេលនៃថ្ងៃឈប់សម្រាកនានារបស់ជាតិ ។

## ២.៣. ការឡើងគ្រងរាជ្យ

រាជានិយមនៃប្រទេសអង់គ្លេសជារបបតែងតាំង ។ មានន័យថារាជាសម្បត្តិនិងត្រូវបានផ្ទេរទៅឲ្យបុត្រច្បង នៃក្សត្រដែលគ្រងរាជ្យ តាមរយៈពេលកំណត់ជាក់លាក់អំពីខ្សែបណ្តោយនៃរាជ្យទាយាទ ។ ប៉ុន្តែមិនមែនក្នុងករណីទាំងអស់សុទ្ធតែដូចគ្នាយ៉ាងនេះទេ ពេលខ្លះការតែងតាំងរាជាទាយាទអាចធ្វើឡើងដោយផ្អែកលើសមត្ថភាពការងារជាក់ស្តែងដែលគួរទុកចិត្តនៅក្នុងរាជ្យវង្ស ។ ក្នុងករណីក្សត្រដែលគ្រងរាជ្យមិនមានរាជបុត្រសោះនោះរាជ្យទាយាទនឹងធ្លាក់លើញាតិវង្សានុវង្ស ដទៃទៀតបាន។



និស្សិតៈ ជិន សារិន, កែ ហុកស្រ៊ុន, ថោង សុវណ្ណ,
នុត វណ្ណៈ, ស ភារុំ, លន់ នីដូណា
សាស្ត្រាចារ្យណែនាំៈ **ម៉ុក ដារ៉ា**

# សេចក្តីសន្និដ្ឋាន

ជារួម ការសិក្សាប្រៀបធៀបរវាងរបបរាជានិយមនៃប្រទេសកម្ពុជា និងអង់គ្លេសបានបង្ហាញឲ្យឃើញថាប្រទេសទាំងពីរនេះ មានលក្ខណៈស្ទើរដូចគ្នាទាំងស្រុង។ មានន័យថា ទាំងកម្ពុជាក្តី ទាំងអង់គ្លេសក្តី សុទ្ធតែប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ គួរបញ្ជាក់ថា របបនេះគឺជាប្រភេទ ឬជាទម្រង់នៃរដ្ឋាភិបាលប្រជាធិបតេយ្យ ដែលព្រះមហាក្សត្រមិនមែនជាបុគ្គលនយោបាយ ឬថាព្រះអង្គជាព្រះប្រមុខរដ្ឋក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញ។ គេអាចនិយាយម្យ៉ាងទៀតថា ព្រះអង្គទ្រង់គ្រងរាជ្យ តែអំណាចទាំងឡាយ រួមមានការកំណត់គោលនយោបាយជាតិទាំងឡាយផងនោះ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ប្រមុខរដ្ឋាភិបាល។

បន្ថែមលើការគ្រងរាជ្យដែលគ្រាន់តែជានិមិត្តរូបនៃឯកភាពជាតិ របស់អង្គព្រះមហាក្សត្ររបបរាជានិយមនៃប្រទេសទាំងពីរនេះ ក៏បានថ្វាយអំណាចក្នុងការរំលាយរដ្ឋសភា និងប្រទានការយល់ព្រមដើម្បី ប្រកាសឲ្យប្រើប្រាស់ច្បាប់ ដែលសភាបានអនុម័តរួចហើយ។ ក៏ប៉ុន្តែ អង្គព្រះមហាក្សត្រត្រូវអនុវត្តន៍នូវសិទ្ធិទាំងនេះ តាមការយល់ព្រមពីរដ្ឋសភា និងរាជរដ្ឋាភិបាល។

និយាយដោយឡែក ភាពផ្សេងគ្នានៃរបបរាជានិយមនៃប្រទេសទាំងពីរ ត្រូវបានរកឃើញចំពោះការឡើងគ្រងរាជ្យសម្បត្តិ។ នៅកម្ពុជា របបរាជានិយមត្រូវបានកំណត់ថាជារបបជ្រើសតាំងដែលត្រូវធ្វើការជ្រើសរើសដោយក្រុមប្រឹក្សារាជ្យសម្បត្តិ។ ផ្ទុយមកវិញ អង់គ្លេសត្រូវបានអនុញ្ញាតឲ្យអង្គព្រះមហាក្សត្រដែលគ្រងរាជ្យ មានព្រះរាជសិទ្ធចាត់តាំងនូវរាជទាយាទដោយព្រះអង្គបានតាមលំដាប់នៃព្រះរាជបុត្រ។

អាចនិយាយបានថាជាចំណុចផ្សេងគ្នាផងដែរ ចំពោះរដ្ឋធម្មនុញ្ញដែលកំណត់ជាក់លាក់អំពីតួនាទី និងអំណាចរបស់ព្រះមហាក្សត្រ។ មហាក្សត្រនៃប្រទេសអង់គ្លេស មានព្រះរាជតួនាទីប្រទានដោយផ្ទាល់ នូវគ្រឿងឥស្សរិយយសជាតិ និងរង្វាន់ដ៏ទៃទៀតសម្រាប់ពលរដ្ឋដែលទទួលបានជោគជ័យក្នុងរឿងសំខាន់ណាមួយ។ លើសពីនេះទៅទៀត ព្រះអង្គទ្រង់មានព្រះរាជតួនាទីប្រកាស និងដឹកនាំការកាន់ទុក្ខ ចំពោះគ្រោះមហន្តរាយផ្សេងៗ ឬការបាត់បង់អាយុជីវិតរបស់កងទ័ពក្នុងសមរភូមិ។

ក្រឡេកមើលរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាឯណោះវិញ ហាក់មានសភាពស្ងប់ស្ងាត់ចំពោះការប្រគល់អំណាចថ្វាយព្រះអង្គក្នុងការប្រទានដោយផ្ទាល់នូវរង្វាន់ ឬគ្រឿងឥស្សរិយយសផ្សេងៗឡើយ។ ត្រង់ប្រការនេះ ក្នុងការអនុវត្តន៍ជាក់ស្តែង គេសង្កេតឃើញមានតែប្រមុខរដ្ឋាភិបាល ជាអ្នក

ប្រគល់នូវកិត្តិយសទាំងអស់នោះ។ នេះអាចនិយាយបានថា ជាចំណុចអវិជ្ជមានមួយ ដែលពេលខ្លះវេទិកានៃការប្រគល់នោះ ប្រមុខរាជរដ្ឋាភិបាល តែងឆ្លៀតឪកាសដើម្បីវាយប្រហារដៃគូរនយោបាយរបស់ខ្លួនទៅវិញ។ ទាំងការដឹកនាំឲ្យប្រារព្ធពិធីកាន់ទុក្ខផ្សេងៗ ជាអាទិ៍ គេហាក់កម្របានឃើញព្រះអង្គចេញព្រះភ័ក្រដោយផ្ទាល់ដែរ។

ចុងបញ្ចប់ ទាំងការប្រទានរង្វាន់ក្តី ទាំងការដឹកនាំប្រារព្ធការកាន់ទុក្ខក្តី គួរតែត្រូវបានធ្វើឡើងដោយអង្គព្រះមហាក្សត្រ ដែលទាំងនេះគួមានចារឹកនៅក្នុងច្បាប់ និងការអនុវត្តជាក់ស្តែង។ ការប្ទានរង្វាន់ដែលបានលើកឡើងខាងលើ រួមទាំងការប្រទានសញ្ញាបត្រដល់និស្សិតដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថាននានានៅកម្ពុជា ដើម្បីជាការលើទឹកចិត្តដល់និស្សិតដែលជាពលរដ្ឋរបស់ព្រះអង្គផង និងដើម្បីលុបបំបាត់វប្បធម៌វាយប្រហារផ្នែកនយោបាយផង៕

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧
- ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សារាជសម្បត្តិ ប្រកាសឲ្យប្រើ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩
- The British Monarchy, a long-standing institution facing modern times
- Ben Aston, What is the Role of the Monarchy in Modern Britain? Can It be Justified Empirically and Theoretically?, 2003
- http://en.wikipedia.org/wiki/Constitution_of_the_United_Kingdom